# សិលាចារឹកប្រាសាទភ្នំជីសូរ្យ K.៣៣

## ១- ព័ត៌មានទូទៅ

ប្រាសាទភ្នំជីសូរ្យស្ថិតនៅលើភ្នំជីសូរ្យ ក្នុងឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ មាន ចម្ងាយ ៤៦ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ប្រាសាទនេះកសាងក្នុងរាជ្យរបស់ព្រះបាទស្រីសូរ្យវម៌្មទេវទី១ នាសតវត្សទី១១ ដើម្បីឧទ្ទិសដល់ព្រះឥសូរ ក្នុងទម្រង់ជាសិវលិង្គព្រះនាមសូរ្យបរមេសូរ និងមានចម្លាក់ឧទ្ទិសដល់ទេពព្រះនារាយណ៍ ព្រះឥន្ទ្រ និងព្រះព្រហ្មផងដែរ[១]។ ប្រាសាទភ្នំជីសូរ្យមានប្រាង្គប្រាំមួយបែរមុខទៅទិសខាងកើតទាំងអស់ និងហោត្រៃឥដ្ឋពីរបែរទៅទិសខាងលិច ហើយថែវរាងចតុកោណកែងសង់ពីថ្មបាយក្រៀម[២]។ ប្រាង្គទិសនិរតីមានពីរក្បែរគ្នា ដែលធ្វើឱ្យបាត់បង់ភាពស៊ីមេទ្រីរបស់ប្រាសាទនោះ លោក លុយណេត៍ ដឺឡាហ្សុងគីយែរ យល់ថាជាប្រាង្គសល់ពីប្រាសាទធ្លាប់សង់នៅទីនេះពីមុនមក[៣] ចំណែកឯលោក Bruguier យល់ថាក៏អាចមកពីសំណង់នេះ កើតក្រោយសំណង់ឯទៀតដែរ ដូច្នេះហើយទើបត្រង់នោះមានកន្លែងចង្អៀត[៤]។

នៅក្នុងសម័យកណ្ដាល ប្រាង្គកណ្ដាលរបស់ប្រាសាទ ទំនងជាត្រូវអ្នកស្រុកកែរូបរាងជាកំពូលចេតិយ ដើម្បីឱ្យក្លាយទៅជាទីតម្កល់ព្រះមហាសារិកធាតុ ដូចបុរាណដ្ឋានព្រហ្មញ្ញសាសនាដទៃទៀត ដែលបានប្រែក្លាយមកជាសាសនដ្ឋានពុទ្ធសាសនា តាមរបត់ជំនឿរបស់សង្គមខ្មែរ។ ប្រាង្គនេះ អ្នកស្រុកហៅថា «វិហារក្នុង» ជាទីស្ថានសំខាន់សម្រាប់វត្តភ្នំជីសូរ្យ។ ប្រាសាទភ្នំជីសូរ្យមានជណ្ដើរបុរាណធ្វើពីថ្មបាយក្រៀមចុះទៅទិសខាងកើតមានគោបុរៈពីរនៅបន្តបន្ទាប់គ្នានៅជើងភ្នំ ឈ្មោះថាប្រាសាទសែនត្មុរ និងប្រាសាទសែនរវាំងឬសែនគូរាំង[៥]។ ខាងកើតនៃគោបុរៈនេះទៀតមានបារាយណ៍មួយដែលអ្នកស្រុកហៅថា «ទន្លេអុំ» ដែលមានទំហំប្រមាណ ៣៨០ម៉ែត្រ x ២០០ម៉ែត្រ។ តាមទំហំទន្លេអុំនិង

[១] Bruno Bruguier, ២០០៩។

[២] https://cisark.mcfa.gov.kh/core/showsite.php?id=666

[៣] លុយណេត៍, ១៩០២។

[៤] Bruno Bruguier, ២០០៩។

[៥] លោក អៃម៉ូនីញេរ៍, ១៩០០ ហៅគោបុរៈទាំងពីរនេះថា «ខ្សិនថ្មុល» និង «ខ្សិនរវាង»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

សណ្ឋានដីនៅតំបន់នោះដែលសម្បូរប្រភពទឹក ទន្លេអុំនេះដឹកឡើងក្នុងអត្ថន័យជានិមិត្តរូបតំណាងឱ្យមហាសមុទ្រ ច្រើនជាងការកសាងប្រព័ន្ធធារាសាស្ត្រសម្រាប់ប្រើប្រាស់។

យោងតាមប្រភពសិលាចារឹកនានា យើងដឹងថា «ភ្នំជីសូរ្យ» កាលពីបុរាណមានឈ្មោះហៅស្រដៀងៗគ្នាថា «ស្រីសូរ្យបព៌ត» «ស្រីសូរ្យគិរី» និង «ស្រីសូរ្យាទ្រិ» ដែលមានន័យថា «ភ្នំនៃព្រះបាទស្រីសូរ្យវម៌្មទេវ(ទី១)»[៦]។ នៅប្រាសាទនេះ អ្នកស្រាវជ្រាវឃើញសិលាចារឹក៤ផ្ទាំង ដែលមានចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹកខ្មែរ K.៣១, K.៣២, K.៣៣ និងK.៣៤។ នៅក្នុងអត្ថបទនេះ យើងជ្រើសរើសយកតែសិលាចារឹកមួយផ្ទាំងប៉ុណ្ណោះមកសិក្សា។

បច្ចុប្បន្ននេះ សិលាចារឹក K.៣៣ រក្សាទុកនៅសារមន្ទីរហ្គីមេត៍ ប្រទេសបារាំង។ អត្ថបទចារជាភាសាខ្មែរបុរាណ កាលបរិច្ឆេទពីរ គឺផ្នែកដំបូង ចុះកាលបរិច្ឆេទនៅមហាសករាជ[៩៣]៧ (គ្រិស្តសករាជ១០១៥) និងនៅផ្នែកបន្ទាប់ ចុះកាលបរិច្ឆេទនៅមហាសករាជ៩៣៩ (គ្រិស្តសករាជ១០១៧) សរុប៣៦បន្ទាត់។ សិលាចារឹកនេះ ធ្លាប់មានមានការសិក្សារួចមកហើយ ដូចជាលោក ហ្សក សេដេស ដែលបានសិក្សាសិលាចារឹក K.៣៣ និង K.៣៤ ចុះផ្សាយក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៣ និងបោះពុម្ពឆ្នាំ ១៩៥១ សរសេរជាភាសាបារាំង។ បន្ទាប់មក លោក ហ្វីលីព ចេណ្ណឺរ បានសិក្សាអំពីសិលាចារឹកនេះនៅក្នុងស្នាដៃលោក Part xml, № 41, និង№ 42 ហើយចេញផ្សាយលើគេហទំព័រ http://sealang.net/ok/corpus.htm[៧] ជាភាសាអង់គ្លេស។

ក្នុងអត្ថបទផ្នែកទី១នៃសិលាចារឹក K.៣៣ ចុះកាលបរិច្ឆេទនៅមហាសករាជ ៩៣៧ (គ្រិស្តសករាជ១០១៥) រៀបរាប់ពីទ្រព្យដែលម្ចាស់សិលាចារឹកនេះយកទៅជាវដីវាស់វែងព្រំប្រទល់ដី ការកសាងអាស្រម គ្រឿងរណ្តាប់បូជាសម្រាប់វេលាសង្ក្រាន្ត និងអ្នកបម្រើដែលឱ្យទៅអាស្រម។ អត្ថបទផ្នែកទី២ ចុះកាលបរិច្ឆេទនៅមហាសករាជ៩៣៩ (គ្រិស្តសករាជ១០១៧) រៀបរាប់អំពីព្រះរាជបន្ទូលព្រះមហាក្សត្រតាមរយៈព្រះអាល័ក្សណ៍

[៦] សូមអាន៖ https://ams.com.kh/khmercivilization/detail/3953

[៧] សូមជ្រើសយកលេខ «K.33/1» និង «K.33/2»។

ដល់ស្តេញសិវាចារ្យនូវស្រម័ថាព្រះអង្គប្រទានដីយោគេន្ទ្រាល័យ និងយោគេន្ទ្របូរ ដែលលោកបានជាវ។ ដីទាំងពីរកន្លែងនេះ គឺជាតង្វាយចំពោះប្រាសាទកម្តែងជគតស្រីវ្រឹទ្ធេស្វរ ហើយលោកបានទុកអ្នកបម្រើនៅកន្លែងទាំងពីរ ថ្វាយជាព្រះរាជធម៌។ បន្ទាប់មក គឺជាសំណូមឱ្យមានតែគាត់ ក្រុមគ្រួសារ និងសន្តានទេ ដែលអាចគ្រប់គ្រងអ្នកបម្រើទាំងនោះ និងបញ្ចប់ដោយការដាក់បណ្តាសាដល់អ្នកបំផ្លាញ និងអ្នករក្សាអំពើបុណ្យរបស់គាត់។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- [៩៣]៧គក្កតគិរាជ្យ៎ធូលិវ្រះបាទកំម្រតេ

២- [ង]អញគ្រិ[៨]សូយ៌្យវម្ម៌ទេវ៎ៈគិន្ទូ[៩]អញដៅភូមិនេះ

៣- តម្រតាញកំបនិទ្រាវ្យនុអញដៅភូមិតំម្រកិតុល១

៤- អំរិតគី[១០]ថ្នូលត្រវាងតិបូវ៌្លូះតគិថ្នូលតិទក្សិន[១១]

៥- ចតិអាគ្រមទូកជ្នះយោគិន្ទ្រាលៃយិទុកិចំនាំស

៦- ងក្រានិតរងកោដេ១អាយិវ្រះរ្នំកំប្រុងខ្ញុំតឱ

៧- យិនេះតៃតំប[១២]តិទុញិតម្រតាញិខ្ញោញិវ្នរខអ្វលិ

៨- ស្វោក១ជ្យង២លិង១០ឆ្នាងលងគោ១ជ្យ[[ង]]២ខលប្រាក់១លិ

៩- ង៣កលិម្វានិរី[១៣]៣ចាន្ទ្យក[១៤]យោ២[១៥]តៃមាយកលិម្វនិ[១៦]រី[១៧]១០

១០- តំម្រ្យកិជ្យង១០ថ្យាំយោ១អំវលិយោ៣វាបិវៃគ្រាមវ្ធិ

---

[៨] លោក សេដេស និងលោក ចេណ្ណឺរ អានជា «គ្រី» តែក្នុងសំណៅផ្តិតគឺ «គ្រិ»។

[៩] លោក សេដេស និងលោក ចេណ្ណឺរ អានជា «នុ» តែក្នុងសំណៅផ្តិតគឺ «នូ»។

[១០] លោក សេដេស និងលោក ចេណ្ណឺរ អានជា «គិ» តែក្នុងសំណៅផ្តិតគឺ «គី»។

[១១] លោក សេដេស និងលោក ចេណ្ណឺរ អានជា «ទក្សិណ» តែក្នុងសំណៅផ្តិតគឺ «ទក្សិន»។

[១២] លោក សេដេស និងលោក ចេណ្ណឺរ អានជា «កប» តែក្នុងសំណៅផ្តិត «តំប»។

[១៣] លោក សេដេស និងលោក ចេណ្ណឺរ អានជា «រិ» តែក្នុងសំណៅផ្តិតគឺ «រី»។

[១៤] លោក សេដេស និងលោក ចេណ្ណឺរ អានជា «ចន្ទ្យក» តែក្នុងសំណៅផ្តិតគឺ «ចាន្ទ្យក»។

[១៥] លោក សេដេស និងលោក ចេណ្ណឺរ អានជា «១» តែក្នុងសំណៅផ្តិតគឺ «២»។

[១៦] លោក សេដេស និងលោក ចេណ្ណឺរ អានជា «កលិម្វានិ» តែក្នុងសំណៅផ្តិតគឺ «កលិម្វនិ»។

[១៧] លោក សេដេស និងលោក ចេណ្ណឺរ អានជា «រិ» តែក្នុងសំណៅផ្តិតគឺ «រី»។

១១- សមយុគនុម្រតាញិខ្វោញិវនុរខអ្វលិនុលោញិត្រ្វាចិ

១២- វលឱយតៃមាយតអញិតៃជម្ន៌តំម្រេកិតុលិម្រតាញិ

១៣- ខ្វោញអចាស្តឱយិតៃបនិហេ[[ំ]] អ្នកិវ្យាធបុរអា

១៤- យតិទុកិនិលច្វាលិ

១៥- ០៩៣៩គក្កមង្សនក្សត្រតគិរាជ្យធូលិវ្រះបាទកំ

១៦- ម្រតេងកំត្វនិអញិគ្រីសូយ៌្យវម្ម៌ទេវគិនុអញិតផ្ទះស្តេ

១៧- ញិគិរាចាយ៌្យវ្នុរស្រមោថ្វាយិសំន្វតិបិវ្រះកំម្រតេងអញិគ្រី

១៨- វីរេន្ទ្រវម្ម៌បង្គំប្បងិនិវេទនចុះវ្រះអាលក្សណតវ្រះកំម្រ

១៩- តេងអញិគ្រីវិរេន្ទ្រវាម្ម៌[18]បន្វលិតអញិបិឱយិគិភូមិយោគេ

២០- ទ្រ្វាលយនុយោគេទ្រ្វបុរមន្តិជៅ០យោគេទ្រ្វាលយតិជៅត

២១- ម្រតាញកំបនិខ្វុ[[ំ]]ម្វាយតំម្រេកិតុលិម្វាយនាយោគេទ្រ្វបុរ

២២- មនិជៅតម្រតាញិខ្វោញិសំវងិកន្តាលិចន្ទ្យាកិ[19]

២៣- កៃម្វាយនេះស្បងតិចាំចំនាំតកំម្រតេងជគតិ

២៤- គ្រីវ្ទ្វេគ្វរខ្ញុំមន្នុក្តអាគ្រមយោគេទ្រ្វាលយតៃ

២៥- ធម្ន[20]តៃមាយតៃនិលតៃតំបតិប្រេឱយិរង្កោជេម្វាយ

២៦- សង្រ្កាន្ត៎នាយោគេ[21]ទ្រ្វបូរ[22]ខ្ញុំតគិតៃកនហ្យងតិទុញិតម្រតា

២៧- ញិខ្វោញិវ្នុរ្អ្វាលិស្រុកៃម្វាយិកល្មានិវិវ្យរតៃកន្សានិ[23]

២៨- តិទុញិក្រៅ្យម្វាយស្រុតបតៃវេទស្រុកៃម្វាយនេះតិប្រេ

២៩- ឱយិចំនាំបុណ្ណ៌មិ[24]អ្នាវស្បារង្កោជេកន្វះប្រតិ

---

[18] លោក សេដេស និងលោក ចេណ្ណឹរ អានជា «វីរេន្ទ្រវម៌្ម» តែក្នុងសំណៅផ្តិតគឺ «វិរេន្ទ្រវាម៌្ម»។

[19] លោក សេដេស និងលោក ចេណ្ណឹរ អានជា «ចន្ទ្យកិ» តែក្នុងសំណៅផ្តិត «ចន្ទ្យាកិ»។

[20] លោក សេដេស និងលោក ចេណ្ណឹរ អានជា «ធម៌្ម» តែក្នុងសំណៅផ្តិត «ធម្ម»។

[21] «គេ» ជួសបន្ថែមនៅខាងលើ ចន្លោះ «យោ» និង «ទ្រ្វ»។

[22] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បុរ» តែក្នុងសំណៅផ្តិត «បូរ»។

[23] លោក សេដេស និងលោក ចេណ្ណឹរ អានជា «កន្ស្យានិ» តែក្នុងសំណៅផ្តិត «កន្សានិ»។

[24] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បូណ៌្ណមី» តែក្នុងសំណៅផ្តិតគឺ «បុណ៌្ណមិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៣០- បក្សនេះស្បង់តិថ្វាយិជាវ្រះរាជធម៌•តិ

៣១- អញិស្វំលេងអាច្ថិអញិតបំនូសិច្វាសិបរិបា

៣២- លវ៌្វអាចិតិអាយត្វតកំលោញិផោងនុកំហ

៣៣- ស្ស•វ៌្វអាច្ថិមាន្ទាអាយត្វតទៃតិលេងសន្ថា

៣៤- នអញិផោងនៅវុវកុលេអញិគិតបរិបាល

៣៥- វិយអ្នក្ថបំបាតិធម៌្មនេះគេស្វេយទោបត

៣៦- គិស--ជ-ន-លិនុសន្ថានវិយតបរិបាលមានូម៌្ម

## ៣- អត្ថបទប្រែសម្រួល

(១-៤) មហាសករាជឆ្នាំ ៩៣៧ ក្នុងរាជ្យធូលីព្រះបាទកម្តែងអញស្រីសូរ្យវម៌្មទេវ គឺខ្ញុំជាវដីនេះពីម្រតាញកំបនៗ ទ្រព្យខ្ញុំជាវដី(នេះគឺ)សំណា១តុលៗ (ដីនេះមានព្រំប្រទល់) អំពីមាត់ត្រពាំងដែលនៅខាងកើតលុះដល់មាត់(ត្រពាំង)ដែលនៅខាងត្បូងៗ

(៥-១៣) សាងអាស្រមដាក់ឈ្មោះយោគិន្ទ្រាល័យ ថ្វាយគ្រឿងវណ្ណាប់បូជាសម្រាប់សង្ក្រាន្ត(មាន)អង្ករ១ដើនៅព្រះភ្នំកំប្រុង ខ្ញុំបម្រើដែលឱ្យ(បម្រើនៅទី)នេះ(មាន)តែតំបដែលទិញពីម្រតាញខ្ញោញវ្នុរខ្លួល(ដោយ)ស្ពក១(ទម្ងន់)២ជញ្ជីង១០តម្លឹង ឆ្នាំងស្ពាន់១(ទម្ងន់)២ជញ្ជីង ខាលប្រាក់១(ទម្ងន់)៣តម្លឹង ក្រមួន(ទំហំ/ទម្ងន់)៣វី សម្បៀក២យោ តៃមាយ(ទិញដោយ)ក្រមួន១០វី សំណា១០ជញ្ជីង ថ្ប៉ាំ១យោ អំវល់៣យោៗ វាបវៃ(ជា)ចាស់ព្រឹទ្ធាចារ្យក្នុងភូមិចូលរួមនឹងម្រតាញខ្ញោញវ្នុរខ្លួលនិងលោញត្រួតពល ឱ្យតៃមាយដល់អញៗ តៃធម្ម(ទិញដោយ)សំណា(១)តុលៗ ម្រតាញខ្ញោញចាស់ឱ្យតៃបន្ថែមៗ អ្នកវ្យាធបូរអោយ ទុក(តៃ)និលចូល(ជាមួយដែរ)ៗ

(១៥-២០) ៙មហាសករាជ៩៣៩ ឆ្នាំមមី នៅក្នុងរាជ្យធូលីព្រះបាទកម្តែងកំដូនអញស្រីសូរ្យវម៌្មទេវ(ទី១) គឺនូវខ្ញុំឈ្មោះស្តេញសិវាចារ្យវ្នុរស្រម៉ថ្វាយសំនូត្រ គប្បីព្រះកម្តែងអញស្រីវីរេន្ទ្រវម៌្មក្រាបថ្វាយបង្គំទូល(ដល់ព្រះមហាក្សត្រ ទ្រង់ក៏)ចុះ(សំបុត្រ)ព្រះអាល័ក្សណ៍ប្រទានដល់ព្រះកម្តែងអញស្រីវីរេន្ទ្រវម៌្ម (យក)ព្រះរាជបន្ទូល(ឱ្យ)ដល់ខ្ញុំ ដើម្បីឱ្យដីយោគេន្ទ្រាល័យនិងយោគេន្ទ្របូរដែលបានជាវ(មកដល់ខ្ញុំតាមក្រាបសុំព្រះរាជទាន)ៗ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(២០-២៣) ៙យោគេន្ទ្រាល័យជាវពីម្រតាញកំបន (ដោយ)ខ្ញុំបម្រើម្នាក់ សំណា១តុល។ នាយោគេន្ទ្របូរជាវពីម្រតាញខ្លោញសំវេងកណ្ដាល (ដោយ)សម្លៀកម្ដៃមួយ។

(២៣-២៨) នេះសុទ្ធសឹង(ជាអ្នក)គ្រឿងវណ្ដាប់រៀបចំ(នៅប្រាសាទ)កម្តែងជគតស្រីព្រឹទ្ធេស្វរ។ ខ្ញុំបម្រើដែលទុកនៅអាស្រមយោគេន្ទ្រាល័យ(មាន)តៃជម្ម តៃមាយ តៃនិលតៃតំប ប្រើ(ឱ្យ)ថ្វាយអង្ករមួយជេ(សម្រាប់)សង្ក្រាន្ត។ នាយោគេន្ទ្របូរ ខ្ញុំបម្រើនៅទីនោះ(មាន)តៃកនហ្សងដែលទិញពីម្រតាញខ្លោញវ្នុរខ្ពល (ដោយ)ស្រូវ២១ ក្រមួន២វី តៃកន្សានដែលទិញ(ដោយគោ)គម្រៀវមួយក្បាល ស្រូវ១០ តៃវេទ(ទិញដោយ)ស្រូវ២១។

(២៨-៣០) (គ្រឿងវណ្ដាប់)ទាំងនេះប្រើ(ឱ្យ)ថ្វាយតាមចំណាំ(នៅថ្ងៃពេញ)បូណ៌មី(និង) ថ្ងៃខែដាច់ នូវអង្ករកន្ទះជេ រៀងរាល់កន្ទះខែ។

(៣០) ទាំងនេះសុទ្ធសឹងថ្វាយជាព្រះរាជធម៌។

(៣០-៣២) ខ្ញុំសូមឱ្យខ្ញុំអាចជាបំនួសនៅបួសថែរក្សា(ទ្រព្យសម្បត្តិនិងគ្រឿងវណ្ដាប់បូជាទាំងនេះ។) ពុំអាចនៅក្រោមការគ្រប់គ្រងរបស់កំលោញទាំងឡាយនិងកំហស្សឡើយក៏ពុំអាចនៅក្រោមការគ្រប់គ្រងអ្នកដទៃដែរ។ សូមឱ្យ(មានតែ)សន្តានខ្ញុំទាំងឡាយ គឺមានក្រុមគ្រួសារខ្ញុំជាអ្នករក្សា។

(៣៥-៣៦) រីអ្នកដែលបំបាត់ធម៌(បុណ្យដែលសាង)នេះ គេនឹងទទួលទោសនៅ... ជាមួយសន្តាន រីអ្នកដែលរក្សា(គេ)បានបុណ្យ។

## ៤- ពន្យល់ពាក្យ

**អញ** ពាក្យ អញ នៅទីនេះមានន័យដូចពាក្យ ខ្ញុំ ប្រើសព្វថ្ងៃដែរ។

**តំម្រក តំម្រ្យក តំម្រេក** សំណា។

**ថ្វលិ** (<តោល "ដោល") ប្រាំងឬទីជម្រាលខ្វាំងនៃទន្លេឬត្រពាំង។

**កលិម្វាន កលិម្វន កល្វាន** ក្រមួន។

**គ្រាមវ្ឫធ** (សំ. គ្រាម "ភូមិ"+ វ្ឫធ "ចាស់, ព្រឹទ្ធ") ចាស់ស្រុក ចាស់ទុំឬចាស់ព្រឹទ្ធាចារ្យក្នុងភូមិ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

សំន្វតិ (<ស្វតិ "សូត្រ") សំបុត្រសម្រាប់សូត្រថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប។

ថ្បូងិ (>ត្បូង) ក្បាល។

ដៅ ដារ, ទិញ។

ក្រ្យា (>ក្រៀវ) នៅទីនេះសំដៅដល់សត្វគោដែលក្រៀវហើយ។

បំន្វសិ បំនួស គឺអ្នកបួស។

ថ្វាសិ បួស។

អាយត្វ (សំ.) ដែលនៅក្រោមការគ្រប់គ្រង, ដែលពឹងផ្អែកលើអ្នកដទៃ។

រ្វ ដូច, ដូចជា។

ធម្ម៌ បុណ្យ, សេចក្តីចម្រើន, អំពើល្អៗល។ ហេតុនេះ ធម៌ ក៏សំដៅដល់ការធ្វើបុណ្យ កសាងអ្វីៗដែលជាកុសលផងដែរ។

កំលោញ ប្រធានគ្រប់គ្រងអ្នកបម្រើនៅប្រាសាទ[២៥]។

## ឯកសារយោង


វង់ សុធារ៉ា ២០១៦ សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ

Aymonier, É. 1900. *Le Cambodge*, I.

Bruguier, B. 2009. *Guide Archéologique du Cambodge*, Tome I.

CISARK. 2009. Phnom Chisor. https://cisark.mcfa.gov.kh/core/showsite.php?id=666

Cœdès, G. 1951. Inscriptions de Phnoṃ Čisór (K. 33, K.34) in *Inscriptions du Cambodge*, Vol. 3. Paris.

Jenner, P. Piédroit of Phnoṃ Čisór in *Part xml, № 41*. http://sealang.net/ok/corpus.htm.

Lunet de Lajonquière, É. 1902. *Inventaire Descriptif des Monuments du Cambodge*, Tome I.


[២៥] វង់ សុធារ៉ា, ២០១៦

# បញ្ជីរូបភាព



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថតៈ ហ៊ុន ឈុនតេង)



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថត៖ ហ៊ុន ឈុនតេង)



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថត៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថតៈ ហ៊ុន ឈុនតេង)



ទិដ្ឋភាពប្រាសាទភ្នំជីសូរ្យ (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទភ្នំជីសូរ្យ K.៣៣

អត្ថបទដោយៈ ហ៊ុន ឈុនតេង